# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការក្រសួងយុត្តិធម៌
លេខ ០១ សរខក្រ

## <u>សារាចរ</u>

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

### <u>ផ្ញើចំពោះ</u>

**ព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង**

**<u>សូមជ្រាប។</u>**

***<u>កម្មវត្ថុ:</u>*** ករណីមន្ទីរឃុំឃាំងនិងពន្ធនាគារខេត្ត ក្រុង ខ្វះទឹកនិងសម្ភារៈប្រើប្រាស់ ។

ខ្ញុំសូមជម្រាបលោកថា នៅតាមបណ្ដាខេត្ត ក្រុង មានឯកឧត្ដមអភិបាលខេត្តរងម្នាក់ទទួលបន្ទុកគ្រប់គ្រង និងត្រួតពិនិត្យពន្ធនាគា ហើយនៅតាមខេត្តនីមួយៗមានអង្គការក្រៅរដ្ឋាភិបាលនានា ដែលកំពុងបំពេញតួនាទីរបស់ខ្លួនដើម្បីអភិវឌ្ឍន៍ជនបទនៅប្រទេសកម្ពុជា ។

ហេតុនេះ ក្នុងករណីខ្វះទឹក ឬសម្ភារៈប្រើប្រាស់នៅមន្ទីរឃុំឃាំង ឬពន្ធនាគារ សូមលោកព្រះរាជអាជ្ញាសរសេរជម្រាបទៅលោកអភិបាលខេត្ត អំពីការខ្វះខាតនេះហើយស្នើលោកអោយសុំទៅអង្គការក្រៅរដ្ឋាភិបាលក្នុងខេត្តអោយជួយឧបត្ថម្ភ ។

ឯចំពោះសារទូរលេខ លេខ ៣០ អក.សទ.៩៥ ដែលប្រធានមន្ទីរក្រសួងយុត្តិធម៌ផ្ញើជូនរួចហើយនោះត្រូវទុកជាមោឃៈ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៦

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

<u>ចម្លងជូន</u>

-ក្រសួងមហាផ្ទៃ
-ក្រសួងសុខាភិបាល
-អភិបាលខេត្ត ក្រុង
-ពន្ធនាគារខេត្ត ក្រុង
-ដើម្បីជូនជ្រាប